**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សារលិខិតថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ
## ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
## បពិត្រព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមថ្លៃថ្លា នៃព្រះរាជពិធីខួបលើកទី១៧នៃការយាងគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទូលព្រះបង្គំយើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវអំណរសាទរយ៉ាងក្រៃលែងប្រកបដោយភក្តីភាពដ៏ជ្រាលជ្រៅជាទីបំផុតថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង។**

ទូលព្រះបង្គំយើងខ្ញុំ សូមព្រះបរមរាជានុញ្ញាតសម្តែងនូវមនោសញ្ចេតនាប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុត ចំពោះព្រះមហាករុណាទិគុណរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ដែលព្រះអង្គតែងបានយកអស់កម្លាំងព្រះកាយពល និងព្រះបញ្ញាញាណមិនខ្លាចនឿយហត់ បំពេញព្រះរាជសកម្មភាព ដ៏វិសេសវិសាលដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជារាស្ត្រជាទីស្រលាញ់របស់ព្រះអង្គ។ ក្រោមព្រះបរមសិរីរាជ្យសម្បត្តិ ដ៏ត្រជាក់ត្រជុំថ្លៃថ្លា និងព្រះមហាករុណាទិគុណប្រកបដោយទសពិធរាជធម៌ដ៏ប្រពៃរបស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់បានជ្រកក្រោមម្លប់ដ៏សុខដុមនៃសន្តិភាព ស្ថិរភាព ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

នាឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លានេះ ទូលបង្គំយើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ សូមធ្វើអភិវន្ទនកិច្ចថ្វាយព្រះពរបវរមហាប្រសើរ និងសូមលើកហត្ថទាំងទ្វេប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាព្រះមហាស្វេតច្ឆត្រ សូមតាមបីបាច់ថែរក្សា ប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរថ្វាយ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** សូម ព្រះអង្គទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់** ទ្រង់ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ច និងព្រះសេយ្យកក្តីដ៏ស្មោះស្ម័គ្របំផុតពីទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស៕

ថ្ងៃ អង្គារ ៦រោច ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
នៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ តុលា ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh